និយ័តករគណនេយ្យនិងសវនកម្ម
Accounting and Auditing Regulator

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## វេទិកាផ្សព្វផ្សាយស្តីពី "នីតិវិធីក្នុងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំតាមប្រព័ន្ធអនឡាញ (E-Filing)"សម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ

ថ្ងៃអង្គារ ១១កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៤

នាព្រឹកថ្ងៃអង្គារ ១១កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹងថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៤ **និយ័តករគណនេយ្យនិងសវនកម្ម** នៃ**អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** បានរៀបចំវេទិកាផ្សព្វផ្សាយស្តីពី **"នីតិវិធីក្នុងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំតាមប្រព័ន្ធអនឡាញ (E-Filing)"** សម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញតាមប្រព័ន្ធអនឡាញ(zoom) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួម នៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព និងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ មន្ត្រីនៃនិយ័តករគណនេយ្យនិងសវនកម្ម ព្រមទាំងវត្តមានរបស់តំណាងសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញសរុបចំនួន ៤៤០នាក់។ វេទិកានេះត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីផ្សព្វផ្សាយជូនដល់នាយកក្រុមហ៊ុន តំណាងក្រុមហ៊ុន សហគ្រាស តំណាងមកពីអង្គការសមាគមនានា បានស្វែងយល់ និងចូលរួមអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្ម និងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំតាមប្រព័ន្ធអនឡាញ (E-Filing) មកនិយ័តករគណនេយ្យនិងសវនកម្ម តាមពេលកំណត់ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធព្រមទាំងប្រកបទៅដោយប្រសិទ្ធភាពខ្ពស់។

ជាកិច្ចចាប់ផ្តើម **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម បានមានមតិស្វាគមន៍ និងថ្លែងសុន្ទរកថាបើកនូវអង្គវេទិកាទាំងមូល ដោយបានវាយតម្លៃខ្ពស់ចំពោះវត្តមានរបស់ ថ្នាក់ដឹកនាំ និងសមាជិកសមាជិកាទាំងអស់ដែលបានចូលរួមក្នុងវេទិកាដ៏មានសារៈសំខាន់នេះ ដែលឆ្លុះបញ្ចាំងឱ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់ក្នុងការស្វែងយល់ និងចូលរួមបន្ថែមក្នុងការអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្ម ក៏ដូចជាការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់សហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញមក **ន.គ.ស.**។ **ឯកឧត្តមអគ្គនាយក** បានគូសបញ្ជាក់ថា **ន.គ.ស.** ការវិវត្តន៍របស់ស្ថាប័នតាំងពីឆ្នាំ ២០០២ ក្រោយពីច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យបានចូលជាធរមានមកមានស្ថាប័ន២ ត្រូវបានបង្កើតឡើងដាក់ឱ្យអនុវត្ត គឺក្រុមប្រឹក្សាជាតិគណនេយ្យ និងវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា។បន្ទាប់មកនៅឆ្នាំ២០១៦ ក៏បានផ្លាស់ប្តូរទៅជាច្បាប់ស្តីពីគណនេយ្យ និងសវនកម្មវិញ។ ជាក់ស្តែង កាលពីឆ្នាំ២០២១ មានការកែប្រែនូវរចនាសម្ព័ន្ធស្ថាប័នដែលធ្វើឱ្យក្រុមប្រឹក្សាជាតិគណនេយ្យ បានក្លាយជានិយ័តករគណនេយ្យនិងសវនកម្ម ស្របតាមច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។ បច្ចុប្បន្ន និយ័តករគណនេយ្យនិងសវនកម្ម ត្រូវបន្តអនុវត្តមុខងារភារកិច្ចបន្តពីក្រុមប្រឹក្សាជាតិគណនេយ្យ និងត្រូវស្ថិតក្រោមអាណាព្យាបាលរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។យ៉ាងណាមិញ **ន.គ.ស.** សង្កេតឃើញថា នៅមានអង្គភាពមួយចំនួននៅមិនទាន់បានយល់ច្បាស់អំពីនីតិវិធីនៃការប្រើប្រាស់ប្រព័ន្ធ។ ហេតុនេះ និយ័តករគណនេយ្យ

និងសវនកម្ម នឹងបន្តរៀបចំវេទិកាផ្សព្វផ្សាយដែលមានរបៀបវារៈបែបនេះទៀតជូនដល់សាធារណៈ ជនស្របតាមផែនការ និងការណែនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** ក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងឱ្យកាន់តែទូលំទូលាយ និងច្បាស់លាស់អំពីច្បាប់និងបច្ចុប្បន្នភាពនៃបទប្បញ្ញត្តិពាក់ព័ន្ធ នឹងវិស័យវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម។ ការលើកកម្ពស់កម្រិតអនុលោមភាពគឺពិតជាមានសារៈសំខាន់ណាស់នៅក្នុងការបង្កើត និងរក្សានូវបរិយាកាសវិនិយោគនៅកម្ពុជាពិសេសគឺការស្តារសេដ្ឋកិច្ចជាតិឡើងវិញ។ ជាក់ស្តែងនាពេលថ្មីៗនេះក្នុងពិធីប្រកាសបើកឱ្យដំណើរការជាផ្លូវការ "សមាគមសហព័ន្ធអ្នកវិនិយោគកម្ពុជា និងពិសាភោជនាហារសាមគ្គី" កាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៤ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានលើកឡើងអំពីការពង្រឹងអនុលោមភាព។ កត្តាសំខាន់មួយដើម្បីពង្រឹងអនុលោមភាពបានលុះត្រាតែវិស័យឯកជនចូលរួមជាមួយរាជរដ្ឋាភិបាល បានន័យថាគ្រប់គ្នាចូលរួមអនុវត្តទៅតាមគោលការណ៍ និងវិធានដែលបានដាក់ចេញនិងឯកភាពគ្នាដើម្បីឱ្យយើងអាចប្រកួតប្រជែងបាន និងអាចរៀបចំផែនការបានកាន់តែប្រសើរជាពិសេស បង្កើតភាពទុកចិត្តរវាងរដ្ឋនិងរដ្ឋ វិស័យឯកជននិងវិស័យឯកជន។ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានបន្ថែមទៀតថាសូមកុំមានការព្រួយបារម្ភនឹងពាក្យអនុលោមភាព ព្រោះអនុលោមភាព មិនមែនមានន័យថារដ្ឋចាំតែចាប់រហូតនោះទេ បង្កើនអនុលោមភាព បង្កើនបរិស្ថានធុរកិច្ចដែលមានភាពប្រាកដប្រជា ភាពច្បាស់លាស់ យូរអង្វែងគឺរដ្ឋមានតួនាទីគាំទ្រភាពជាដៃគូការជួយគិត ជួយធ្វើ និងជួយអនុវត្ត។ ការរួមគ្នារវាងវិស័យឯកជន និងរាជរដ្ឋាភិបាល រួមគ្នាដើម្បីបង្កើតបរិស្ថានវិនិយោគនៅកម្ពុជាប្រកបដោយភាពទាក់ទាញ និងភាពកក់ក្តៅឱ្យវិនិយោគទាំងអស់នៅក្នុងនិងក្រៅប្រទេសរីកចម្រើន។ មិនត្រឹមតែប៉ុណ្ណោះក្នុងនិកាសប្រារព្ធទិវាជាតិសហគ្រាសធុនមីក្រូតូច និងមធ្យមលើកទី១ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានបន្ថែមថា "អនុលោមភាពនៃច្បាប់និងបទដ្ឋានគតិយុត្ត និងការកាន់បញ្ជិកាគណនេយ្យគួរត្រូវបានលើកតម្កើង និងចាត់ទុកជាការវិនិយោគដែលនឹងទទួល បានផលត្រឡប់មកវិញចៀសជាងជាបន្ទុកនៃការធ្វើធុរកិច្ច"។

ឆ្លៀតក្នុងនិកាសនេះ **ឯកឧត្តមអគ្គនាយក** បានលើកឡើងអំពីច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ បានកំណត់នូវកាតព្វកិច្ចជាសារវន្តចំនួន៣ សម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញអនុវត្ត រួមមាន÷

- **ការកាន់បញ្ជីគណនេយ្យត្រឹមត្រូវ**
- **ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យជាធរមាន និង**
- **ការដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យតាមលក្ខខណ្ឌកំណត់ដោយច្បាប់។**

***កាតព្វកិច្ចកាន់បញ្ជីគណនេយ្យ, កាតព្វកិច្ចរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាជាធរមាន និងកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យស្របតាមលក្ខខណ្ឌកំណត់ព្រមទាំងកាតព្វកិច្ចដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក ន.គ.ស. ជាមូលដ្ឋានដ៏សំខាន់សម្រាប់ការបំពេញកាតព្វកិច្ចសារពើពន្ធ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។***

ត្រង់ចំនុចនេះ **ឯកឧត្តមអគ្គនាយក** បានធ្វើការកត់សម្គាល់ថាការដាក់ទោសទណ្ឌ ឬពិន័យ ដល់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ មិនមែនជាបំណងប្រាថ្នាចម្បងរបស់និយ័តករគណនេយ្យនិងសវនកម្មនោះទេ។ គោលបំណងរបស់និយ័តករគឺចង់បាន ***"ការបង្កើតប្រព័ន្ធគណនេយ្យមួយដែលរឹងមាំ មានតម្លាភាព និងអាចជឿទុកចិត្តបាន"*** តាមរយៈការប្រកាន់ភ្ជាប់នូវកាតព្វកិច្ចខាងលើឱ្យបានខ្ជាប់ខ្ជួន។ ជាលទ្ធផល ទោះបីពុំទាន់មានការវាយតម្លៃជាផ្លូវការ និងពុំទាន់មានទិន្នន័យជាក់លាក់នៅឡើយក៏ដោយ ក៏អាចវាយតម្លៃបានថាមានសហគ្រាសប្រមាណ ៣០% បានចូលរួមអនុវត្ត

កាតព្វកិច្ច ហើយទន្ទឹមនេះក៏មានសហគ្រាសមួយចំនួន បានទទួលរងពិន័យអន្តរការណ៍រួចទៅហើយ អនុលោមតាមអនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម។

មុននឹងបញ្ចប់ **ឯកឧត្តមអគ្គនាយក** បានផ្តាំផ្ញើទៅកាន់សហគ្រាសនិងអង្គភាព នៅក្នុងឆ្នាំ២០២៤នេះ សហគ្រាស និងអង្គភាពដែលរងសវនកម្មឯករាជ្យមានកាតព្វកិច្ចរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យជាធរមាន និងត្រូវដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ និងដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស.** មិនឱ្យហួស ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៤ បន្ទាប់ពីការិយបរិច្ឆេទបិទបញ្ជីគណនេយ្យ ប៉ុន្តែ **ន.គ.ស.** បានសម្រេចផ្តល់ពេលវេលាបន្ថែមចំនួន ៣០ថ្ងៃ ក្នុងការដាក់បញ្ជូលរបាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស.** មិនឱ្យហួសថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៤។ម្យ៉ាងវិញទៀត សហគ្រាស និងអង្គភាពរងសវនកម្ម អាចដាក់លិខិតស្នើសុំពន្យារពេលបញ្ចប់ការងារសវនកម្មឯករាជ្យមក **ន.គ.ស.** មិនឱ្យហួស ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៤។

ជាចុងបញ្ចប់ **ឯកឧត្តមអគ្គនាយក** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមានរបស់សមាជិកសមាជិការនៃអង្គវេទិកាទាំងមូល ដែលបានចំណាយពេលវេលាយ៉ាងមានតម្លៃក្នុងការចូលរួមក្នុងវេទិកាស្តីពី **“នីតិវិធីក្នុងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំតាមប្រព័ន្ធអនឡាញ (E-Filing)” សម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ** នេះ។ **ឯកឧត្តមអគ្គនាយក** សង្ឃឹមយ៉ាងមុតមាំថា ក្រោយពីបញ្ចប់វេទិកានេះ សមាជិកសមាជិកានៃអង្គវេទិកា នឹងយល់បានកាន់តែច្បាស់អំពីច្បាប់នីតិវិធី និងយន្តការនៃ**ការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំតាមប្រព័ន្ធអនឡាញ** មក **ន.គ.ស.** ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងបានជូនពរសមាជិកសមាជិការនៃអង្គវេទិកា ដែលបានចូលរួមទាំងអស់ទទួលបាននូវសុខភាពល្អ កម្លាំងពលំមាំមួន និងសម្រេចបានជោគជ័យគ្រប់ភារកិច្ច។